01703090

F71/1/1/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ភាគីដាក់ឯកសារ៖** ការិយាល័យរដ្ឋបាល

**ដាក់ជូន៖** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 08 / 2022
ម៉ោង (Time/Heure): 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖** **សាធារណៈជាមួយឧបសម្ព័ន្ធសម្ងាត់**

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ៖**

**ចំណាត់ថ្នាក់ប្រភេទឯកសារ៖**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

**សេចក្ដីសង្ខេបរបស់ការិយាល័យរដ្ឋបាល ស្ដីពីសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារក្នុងសំណុំរឿង ០០២**

---

**ដាក់ដោយ៖**

**ការិយាល័យរដ្ឋបាល អ.វ.ត.ក**

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Fergal GAYNOR (បម្រុង)

**សហមេធាវីការពារក្ដី ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSE

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

លោក ពេជ្រ អង្គ

លោកស្រី Falguni DEBNATH

១. អនុលោមតាមសេចក្តីអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល ការិយាល័យរដ្ឋបាលសូមផ្តល់ជូនសេចក្តីសង្កេតរបស់ខ្លួន ស្តីពីសំណើសុំគោលការណ៍ណែនាំ សម្រាប់ការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារក្នុងសំណុំរឿង ០០២[1]។

២. ការិយាល័យរដ្ឋបាលគាំទ្រដល់ការធ្វើចំណាត់ប្រភេទជាសាធារណៈឱ្យបានកាន់តែទូលំទូលាយតាមដែលអាចធ្វើបាន ចំពោះកំណត់ហេតុនានា អនុលោមតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក វិធានការការពារដែលបង្គាប់តាមផ្លូវតុលាការ និងសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ ការិយាល័យរដ្ឋបាលយល់ឃើញថា ជំហាននេះនឹងទទួលបានជោគជ័យក្នុងការដោះស្រាយក្តីរំពឹងរបស់សាធារណជនដែលចង់ឱ្យមានតម្លាភាពក្នុងកិច្ចការរដ្ឋបាលនៃអង្គជំនុំជម្រះ។ វាក៏បង្ហាញផងដែរអំពីការប្តេជ្ញាចិត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការថែរក្សា និងគ្រប់គ្រងបណ្ណសាររបស់ខ្លួន រួមទាំងសម្ភារៈដែលបានធ្វើចំណាត់ប្រភេទជាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន ព្រមទាំងធានាឱ្យបានថា បណ្ណសាររបស់ខ្លួន "សាធារណជនអាចចូលមើលបានយ៉ាងទូលំទូលាយ" ស្របទៅនឹងមាត្រា ២(១) និងមាត្រា ៣ នៃកិច្ចព្រមព្រៀងបន្ថែម ទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប-រ.រ.ក។

៣. បើតាមអង្គភាពបណ្ណសារ គិតមកត្រឹមពេលរៀបចំសេចក្តីសង្កេតនេះ ស្ថានភាពចំណាត់ប្រភេទឯកសារក្នុងសំណុំរឿងមានដូចតទៅ៖

| សំណុំរឿង | សាធារណៈ | សម្ងាត់ | សម្ងាត់បំផុត | សរុប | % នៃសំណុំរឿងជាសាធារណៈ |
|---|---|---|---|---|---|
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ | - | ៣.៨៤០ | - | ៣.៨៤០ | 0% |
| ០០១ | ៨.០៥៨ | ១០.៥៥១ | ២៤១ | ១៨.៨៥០ | ៤២,៧% |
| ០០២ | ៣២.២៨៨ | ១០៦.៨៣៩[2] | ៤.៧៧៩[3] | ១៤៣.៩០៦ | ២២,៤% |
| ០០៣ | ២.៣១៥ | ២១.៨២៣ | ៩៤ | ២៤.២៣២ | ៩,៦% |
| ០០៤ | ២.៦០៩ | ៣៥.១៤៣ | ៤៥ | ៣៧.៧៩៧ | ៦,៩% |

[1] អនុស្សរណៈអន្តរការិយាល័យ *"ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២"* ឯកសារ F71/1/1 ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២។

[2] រួមទាំងឯកសារចំនួន ១ (មួយ) ដែលធ្វើចំណាត់ប្រភេទជាឯកសារ "សម្ងាត់បណ្តោះអាសន្ន"។

[3] រួមទាំងឯកសារចំនួន ៤ (បួន) ដែលធ្វើចំណាត់ប្រភេទជាឯកសារ "សម្ងាត់បំផុតបណ្តោះអាសន្ន"។

| | | | | | |
|---|---|---|---|---|---|
| **០០៤/១**[4] | ១.២៨៣ | ២៧.៧៩៦ | ២៤ | ២៩.១០៣ | **៤,៤%** |
| **០០៤/២**[4] | ១.៩៨៦ | ៣៣.៤២២ | ៥៣ | ៣៥.៤៦១ | **៥,៦%** |
| **សំណុំរឿងពិសេស** | ៦២៦ | ៧៨៧ | ២៤៧ | ១.៦៦០ | **៣៧,៧%** |
| **សរុបរួម** | ៤៩,១៦៥ | ២៤០.២០១ | ៥.៤៨៣ | ២៩៤.៨៤៩ | **១៦,៧%** |

*ចំនួនឯកសារពីសំណុំរឿងមួយទៅសំណុំរឿងមួយទៀត ដោយការធ្វើចំណាត់ប្រភេទ (មិនឆ្លុះបញ្ចាំងចំនួនទំព័រទេ)។*

៤. ការិយាល័យរដ្ឋបាលពុំមែនជាភាគីក្នុងកិច្ចដំណើរការនីតិវិធីទេ ហេតុនេះការិយាល័យនេះសូមកម្រិតត្រឹមតែផ្តល់ជូននូវយោបល់ទូទៅដែលថា ឯកសារនានាដែលស្ថិតក្នុងប្រភេទដូចខាងក្រោម ដែលអាចមានតម្លៃជាប្រវត្តិសាស្ត្រចំពោះកម្ពុជា ឬកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញ គួរត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ស្របទៅនឹងនីតិវិធីជាធរមាន៖

ក. ឯកសារសម្ងាត់នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានធ្វើចំណាត់ប្រភេទជាសាធារណៈក្នុងសំណុំរឿងផ្សេងទៀត (សូមមើល **ឧបសម្ព័ន្ធ** ក)។

ខ. សំណុំរឿងពិសេសពាក់ព័ន្ធនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២ (សូមមើល **ឧបសម្ព័ន្ធ ខ**)។

គ. វត្ថុតាងទាំងអស់ (E3) រួមទាំងសម្ភារៈជាខ្សែវីដេអូ (E3/*R) ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជាពិសេសបណ្តាវត្ថុតាងដែលបានលើកយោងនៅក្នុងសាលក្រម ឬសាលដីកា។

ឃ. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងភស្តុតាងជាមូលដ្ឋាន ដែលលែងតម្រូវឱ្យមានមានការធ្វើចំណាត់ប្រភេទជាសម្ងាត់តទៅទៀត។

ង. កំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹក សេចក្តីថ្លែងការណ៍ សុន្ទរកថា និងការបោះពុម្ពផ្សាយដោយជនជាប់ចោទ ឬទណ្ឌិតទាំងអស់ ឬពាក់ព័ន្ធនឹងជនទាំងនោះ។

ច. សេចក្តីសម្រេចរបស់តុលាការ ដីកា សាលក្រម សាលដីកា សំណើរបស់ភាគី ដែលឯកសារទាំងនោះពាក់ព័ន្ធនឹងជនជាប់ចោទ ឬទណ្ឌិត។

ឆ. ឯកសារស៊ើបអង្កេត (រួមទាំងរបាយការណ៍ចុះពិនិត្យដល់ទីតាំងឧក្រិដ្ឋកម្ម និងផែនទី) ពាក់ព័ន្ធទីតាំងដែលសហចៅក្រមស៊ើបអង្កេតបានចុះទៅស៊ើបអង្កេត *ជាពិសេស* បណ្តាទីតាំងដែលស្ថិតនៅ*ខាងក្រៅ*វិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និង ០០២/០២

[4] រួមទាំងឯកសារដែលបានដាក់មុនពេលមានដីកាសម្រេចបំបែកសំណុំរឿងចេញពីសំណុំរឿង ០០៤។

ដែលអង្គហេតុត្រូវបានកម្រិតដោយដីកាសម្រេចបំបែកសំណុំរឿង ឬដែលត្រូវបានដកចេញពីដីកាដំណោះស្រាយ ឬការជំនុំជម្រះ តាមវិធីផ្សេងទៀត។

ជ. ឯកសារកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជា និងឯកសារសហសម័យទាំងអស់ (រួមទាំងកំណត់ហេតុប្រជុំ ការបោះពុម្ពផ្សាយរបស់រដ្ឋាភិបាល របាយការណ៍ សារទូរលេខ បញ្ជីអ្នកទោស ចម្លើយសារភាព សេចក្តីថ្លែងការណ៍សាធារណៈ។ល។) ដែលមានតម្លៃយ៉ាងធំធេងផ្នែកប្រវត្តិសាស្ត្រ។

៥. ការិយាល័យរដ្ឋបាលត្រៀមខ្លួនរួចជាស្រេច ក្នុងការសម្របសម្រួលដំណើរការធ្វើចំណាត់ប្រភេទឡើងវិញ តាមរយៈអង្គភាពនានារបស់ខ្លួន តាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ។

សូមលោក-លោកស្រីចៅក្រមមេត្តាទទួលយកសេចក្តីសង្កេតនេះដោយក្តីគោរព។

| | | | |
|---|---|---|---|
| ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ | **ឯ.ឧ ក្រាញ់ តូនី**<br>ប្រធានរដ្ឋបាលស្តីទី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | [signature] |
| | **Knut Rosandhaug**<br>អនុប្រធានរដ្ឋបាល | | [signature] |



01703093